# ដំណើរវិវត្ត
# នៃអាពាហ៍ពិពាហ៍ខ្មែរ


ក្រុមស្រាវជ្រាវ

ឆយ យីហ៊ាង

ប្រេង ពិសិដ្ឋ ‍ ‍ ‍ ‍ លេង ណៃគីម

ម៉ិល វាសនា ‍ ‍ ‍ ‍ ភិន ណារ៉ុង

ឈិត ភក្តី ‍ ‍ ‍ ‍ ជា មុនីឫទ្ធិ



រក្សាសិទ្ធិ



ភ្នំពេញ ៧ មករា ២០០៨



www.elibraryofcambodia.org

ឆយ ឃីហ៊ាង

ប្រែង ពិសិដ្ឋ លេង ណៃគីម

ម៉ិល វាសនា ភិនណារ៉ុង

ឈិត ភក្តី ជា មុនីឫទ្ធិ

ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ

ជំពូកទី១

ហេតុនៃពិធីកិច្ចមង្គលមួយចំនួនក្នុងអាពាហ៍ពិពាហ៍ខ្មែរ

# ១. អាពាហ៍ពិពាហ៍ជាការកសាងគ្រួសារ

## ១.១. អាពាហ៍ពិពាហ៍ជាអ្វី?

យើងមិនទាន់ដឹងច្បាស់ថា សង្គមយើងចាប់រៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យណាឡើយ។ តើអាពាហ៍ពិពាហ៍ខ្មែរមានត្រឹមសម័យព្រះថោងនាងនាគឬមានមុនសម័យនេះ?នេះជាចម្ងល់របស់យើង? យើងមិនទាន់យល់អំពីព្រឹត្តិការណ៍ផ្សេងៗនៅក្នុងសង្គមយើងនៅពេលមុនមានអាពាហ៍ពិពាហ៍។ ប៉ុន្តែអាពាហ៍ពិពាហ៍មានអត្ថន័យសំខាន់ណាស់ក្នុងជីវិតមនុស្សខ្មែរ។

ខ្មែរប្រើពាក្យអាពាហ៍ពិពាហ៍ ឬអាវាហ៍ពិវាហ៍ (អាវាហះពិវាហះ) សំគាល់ពិធីនេះដែរ។

អាវាហះ = ការនាំកូនស្រីមកផ្ទះខាងប្រុស។

ពិវាហះ = ការនាំកូនប្រុសមកផ្ទះខាងស្រី។

អាវាហាពិវាហះ = មង្គលការកូនប្រុសស្រីដែរនាំមក ហើយនាំមកវិញ(ពីរលើក)។

តាមប្រពៃណីខ្មែរគេនាំកូនប្រុសមកខាងលំនៅស្ថានកូនស្រីមុន(អាវាហះមង្គល) ហើយនាំកូនស្រីទៅឯរោងកូនប្រុសវិញ (វិវាហាមង្គល) ។ ប៉ុន្តែទោះបីគេធ្វើត្រឹមតែវិវាហាមង្គល (នាំកូនប្រុសមកខាងកូនស្រី) តែម្យ៉ាង ក៏គេនិយមហៅគួបទាំងពីរថា អាវាហ៍វិវាហ៍ដែរ។[១]

នៅក្នុងជីវិតរបស់យើង យើងយល់ថា អាពាហ៍ពិពាហ៍មានអត្ថន័យដូចខាងក្រោម៖



www.elibraryofcambodia.org

- អាពាហ៍ពិពាហ៍បង្ហាញឲ្យឃើញថា សេចក្តីស្នេហារវាងបុរសនិងស្ត្រីដែលតាក់តែងឡើងដោយធម្មជាតិ ត្រូវបានលាតត្រដាងនៅចំពោះមហាជន ធ្វើអោយមហាជនទទួលស្គាល់និងគាំទ្រតាមផ្លូវចិត្ត ផ្លូវកាយនិងរួមចំណែកឧបត្ថម្ភខាងសំភារៈ។

- អាពាហ៍ពិពាហ៍ជាការផ្សារភ្ជាប់សេចក្តីស្នេហារវាងបុគ្គលនិងបុគ្គល។ ហេតុនេះវាមានលក្ខណៈឯកជន។ ប៉ុន្តែដើម្បីការពារសុវត្ថិភាពរបស់គូស្វាមីភរិយា អាជ្ញាធរនៅតាមភូមិ ឃុំ ស្រុកបានទទួលស្គាល់តាមផ្លូវច្បាប់ ដែលមិនអាចអោយអ្នកដទៃប៉ះបានឡើយ។

- អាពាហ៍ពិពាហ៍ស្មោះស្ម័គ្រដែលគ្មានការបង្ខិតបង្ខំ ត្រូវបានគេចាត់ជាកាតព្វកិច្ចចម្បងមួយនៅក្នុងគ្រួសារ និងសហគមន៍។ សាមីខ្លួន មាតាបិតា បងប្អូននិងញាតិសន្តាន មានអារម្មណ៍រីករាយចំពោះកាតព្វកិច្ចនេះ។

- អាពាហ៍ពិពាហ៍បានបង្ហាញអោយឃើញពីការសងគុណរបស់បុត្រធីតាចំពោះមាតាបិតា។

អាពាហ៍ពិពាហ៍បង្ហាញអោយឃើញអំពីតំលៃរបស់មនុស្ស។ ចំណែកសត្វឥតបានរៀបអាពាហ៍ពិពាហ៍ឡើយ ទោះបីវាមានសន្ទាវគតិស្នេហាដូចមនុស្សក៏ដោយ។

## ១.២. អាពាហ៍ពិពាហ៍និងការកសាងគ្រួសារ

នៅសង្គមខ្មែរ ពិធីរៀបអាពាហ៍ពិពាហ៍ជាប្រពៃណីមួយដែលមានបញ្ញតិប្រហែលគ្នានឹងកាតព្វកិច្ចដែរ ព្រោះអ្នកដែលបានគ្នាជាប្តីប្រពន្ធត្រូវតែឆ្លងកាត់អាពាហ៍ពិពាហ៍ បើគេចវេសពិធីនេះនឹងត្រូវគេចាត់ទុកថា ជាអ្នកគ្មានសិរីសួស្តី គ្មានកិត្តិយស។

បើតាមប្រពៃណីខ្មែរ កូនប្រុសកូនស្រីដែលបានរៀបអាពាហ៍ពិពាហ៍ពេញច្បាប់ តែងមានអារម្មណ៍ស្ងប់ស្ងាត់ រីករាយនិង



www.elibraryofcambodia.org

[១]អ្នកស្រី ត្រឹង ងា: អរិយធម៌ខ្មែរ, ថ្នាក់ទីបញ្ចប់, បោះពុម្ពលើកទី៣, គ.ស១៩៧៤, ព.ស២៥១៨ ទំព័រ១៧៥

មានជំនឿលើជីវិតរស់នៅរបស់ខ្លួន ដែលពាក្យខ្មែរហៅថា "*ការរស់នៅពេញមុខ* "។ ផ្ទុយទៅវិញ ចំពោះគូស្វាមីភរិយាដែលមិនបានរៀបអាពាហ៍ពិពាហ៍ ទោះបីមានទ្រព្យសម្បត្តិច្រើនក៏ដោយ ក៏តែងមានការពេបជ្រាយខ្លះៗពីសង្គមដែរ។ នៅពេលដែលគេមានកូន កូននោះត្រូវបានគេហៅថា "*កូនក់គខាន់ស្លា*" ។ កត្តានេះបណ្តាលឲ្យបុរសស្ត្រីដែលស្រឡាញ់គ្នាតាមបែប "*មិនពេញមុខ*"។ ចាកចោលលំនៅស្ថាន ភូមិ ទៅរស់នៅទីកន្លែងឆ្ងាយៗ នេះជាការផ្តន្ទាទោសរបស់សង្គមចំពោះគូស្វាមីភរិយាដែលមិនបានរៀបអាពាហ៍ពិពាហ៍។ ហេតុនេះក្នុងចិត្តគំនិតខ្មែរ មាតាបិតាមានភាតព្វកិច្ចរៀបចំអាពាហ៍ពិពាហ៍ឲ្យបុត្រធីតា ដើម្បីបន្តការកសាងគ្រួសាររបស់គេ។

## ២.រឿងនិទានទាក់ទងនឹងពិធីកិច្ចមង្គលមួយចំនួន

មានមតិមួយចំនួនលើកឡើងខុសៗគ្នា ពីប្រភពនាំឲ្យមានអាពាហ៍ពិពាហ៍ខ្មែរ។ មតិខ្លះថា អាពាហ៍ពិពាហ៍ខ្មែរយកលំនាំតាមពិធីអាពាហ៍ពិពាហ៍ *ព្រះរាម* និង *នាងសីតា* របស់មហាកវី *មិថិលា*។ មតិខ្លះថា យកគម្រាប់តាមព្រះវេសន្តរ កាលទ្រង់រៀបអភិសេកចៅ *ជាលី* និង *ក្រឹស្នា*។ ឯមតិខ្លះទៀតថា យកគម្រាប់តាមពិធីអភិសេក ព្រះថោង និង នាង ទាវផ្តី។

លោក ម៉ម ប៉ុណ្ណា (នៅក្នុងសៀវភៅ Les rites de marriage traditionnel Khmer) មនុស្សចេះរៀបអាពាហ៍ពិពាហ៍តាំងពីមនុស្សចេះអៀនខ្មាសនិងចេះស្រឡាញ់កិត្តិយស ដោយសម្អាងលើព្រហ្មញ្ញសាសនា។

ពិធីកិច្ចមង្គលផ្សេងៗក្នុងអាពាហ៍ពិពាហ៍ខ្មែរមានមូលដ្ឋានពីរឿងព្រេងនិទានខ្មែរ គឺមិនមែនធ្វើឡើងដោយគ្មានខ្លឹមសារឡើយ។ រឿងព្រេងមួយចំនួននាំឲ្យមានកិច្ចមង្គលទាំងនេះ មានដូចខាងក្រោម។



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*

*ប្រៃង ពិសិដ្ឋ លេង ណៃគីម*

*ម៉ិល វាសនា ភិនណារ៉ុង*

*ឈិត ភក្តី ជា មុនីឫទ្ធិ*



## ២.១.រឿងបុរសឃ្វាលគោនិងបុរសឃ្វាលក្របី(ទាក់ទងនឹងពិធីស៊ីស្លាដក់-ស្លាកន្សែង)

មានហេតុដំណាលថា កាលដើមឡើយមានបុរសពីរនាក់ទៅឃ្វាលគោនិងឃ្វាលក្របីជួបគ្នា ហើយសុំគ្នាធ្វើជាក្លើៗ ក្លើម្នាក់ថា មានកូនស្រី ឯក្លើម្នាក់ទៀតថា មានកូនប្រុសៗ ដូច្នេះក៏និយាយសុំផ្សំផ្គុំកូននឹងកូនឲ្យធ្វើជាគូសម្ព័ន្ធនឹងគ្នាៗ បុរសមានកូនស្រីយល់ព្រម ទើបបុរសមានកូនប្រុសស្រាយយកស្លាចងផចថ្នក់ ដក់នឹងកន្សែង មកឲ្យបុរសមានកូនស្រីនោះស៊ី ហើយថា ត្បិតនៅក្នុងព្រៃខ្លួនគ្មានអ្វីជាគ្រឿងបញ្ចាំចិត្តទេ សុំឲ្យសម្លាញ់ស៊ីស្លាជាប់នឹងកន្សែងនេះមួយមាត់ចុះ ដើម្បីជាកិច្ចសះញ្ញាដល់គ្នានឹងគ្នាតទៅៗ បុរសដែលមានកូនស្រីទទួលតាមៗ

ដូច្នេះហើយ ទើបមានកិច្ចពិធីពិសាស្លាកន្សែងនៅក្នុងពិធីអាពាហ៍ពិពាហ៍ខ្មែររហូតសព្វថ្ងៃៗ វាជាសក្ខីភាពបញ្ជាក់ថា មាតាបិតាកូនប្រុស កូនស្រី យល់ព្រមធ្វើជាដន្លង ផ្សារសាច់ផ្សារឈាមនឹងគ្នាៗ

## ២.២.រឿងទាក់ទងនឹងពិធីសែនក្រុងពាលី

មានការដំណាលខុសគ្នារវាងសៀវភៅ *ប្រជុំរឿងព្រេងខ្មែរ ភាគ៩* និងការចេះចាំរបស់លោកអាចារ្យមួយចំនួន អំពីរឿងព្រេងទាក់ទងនឹងកិច្ចសែនក្រុងពាលីនេះៗ យើងនឹងលើកយកការដំណាលនេះ មកបង្ហាញដូចខាងក្រោម៖

សៀវភៅ *ប្រជុំរឿងព្រេងខ្មែរ ភាគ៩* ដំណាលថាកាលនោះព្រះសមណគោតមបរមពោធិសត្វកើតជាតិស្តេចស្វាខ្មៅ ឯស្តេចក្រុងពាលីជាស្តេចស្វាសៗ ស្តេចស្វាទាំងពីរបានក្លាយជាសំលាញ់នឹងគ្នាៗ ស្តេចស្វាសបានតាំងថា"បើសម្លាញ់បានត្រាស់ដឹងនូវសម្ពោធិញ្ញាណទៅអនាគតនោះក៏សូមកុំឲ្យផុតពីទំនុកបម្រុងទេវិញទៅមកឡើយ"ៗ

លុះជាតិក្រោយមក បរមពោធិសត្វបានត្រាស់ជាព្រះពុទ្ធ ឯស្តេចស្វាសកើតជាស្តេចក្រុងពាលី មានខ្លួនជាមនុស្សពាក់កណ្តាលសត្វៗ ស្តេចក្រុងពាលីលើកខ្លួនជាស្តេចបរមចក្រ វាតទីយកទឹកដីទ្វីបទាំង៤កាន់កាប់ៗ គ្រានោះស្តេចក្រុងពាលីក្រេវក្រោធនឹងព្រះពុទ្ធ ដោយចោទថា ដើរបញ្ឆោះបញ្ឆោលមនុស្សនិងទន្ត្រានយកទឹកដីៗ ព្រះពុទ្ធពន្យល់និងរៀបរាប់ពីអតីតជាតិ ដោយបង្ហាញថា



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*

*ប្រែង ពិសិដ្ឋ* *លេង ណៃគីម*

*ម៉ិល រ៉ាសនា* *ភិនណារ៉ុង*

*ឈិត ភក្តី* *ជា មុនីឫទ្ធិ*



ព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធ ទើបខំដើរប្រោសសត្វឲ្យរួចផុតពីចំណងទុក្ខ។ យល់សព្វហើយ ស្តេចក្រុងពាលីបានសុំខ្លួនជាបុព្វជិតក្នុងសាសនាព្រះពុទ្ធ។ ដោយស្តេចក្រុងពាលីមានរូបជាមនុស្សពាក់កណ្តាលសត្វ ព្រះពុទ្ធជួយសង្គ្រោះបានត្រឹមតែសីល៥ កម្មបទ១០ ជាពូជទៅអនាគតប៉ុណ្ណោះ។ ព្រះពុទ្ធបានប្រកាសដល់ពុទ្ធបរិស័ទទាំងឡាយឲ្យមានចិត្តសទ្ធាជ្រះថ្លា ឧទ្ទិសចំណែកកុសលជូនស្តេចក្រុងពាលី ដើម្បីឲ្យឆាប់បានរួចផុតពីជាតិថោកទាបនេះ។ តមក ពុទ្ធបរិស័ទតែងឧទ្ទិសកុសលជូនស្តេចក្រុងពាលីជាដរាប។

---

២ *ប្រជុំរឿងព្រេងខ្មែរ ភាគ៩.* ពុទ្ធសាសនាបណ្ឌិត.(បោះពុម្ពឡើងវិញដោយក្រសួងអប់រំយុវជន និងកីឡា). ភ្នំពេញ. ២០០៣. ទំព័រ២៥-៣០

ហេតុនេះ តាមការនិទានខាងលើ វាជាការឧទ្ទិសកុសលកុសលជូនស្តេចក្រុងពាលីឲ្យរួចផុតពីភាពថោកទាប មិនមែនជាការសែនខ្មោចបារមីក្រុងពាលីទេ។

តាមការដំណាលរបស់លោកអាចារ្យ *សួន សុន* ថា៖

ការសម័យព្រះពុទ្ធ ពេលទ្រង់យាងចូលនគរគោកធ្លក ក៏បានជួបស្តេចក្រុងពាលីដែលជាម្ចាស់ទឹកម្ចាស់ដី ហើយក៏បានសុំដីដើម្បីរស់នៅ។ ពេលនោះ ស្តេចក្រុងពាលីក៏បានយល់ព្រមឲ្យដីព្រះពុទ្ធ ដោយការឈានវាស់៣ជំហាន។ ដោយបារមី ព្រះពុទ្ធឈាន៣ជំហាន ក៏អស់ទឹកដីទាំងមូល។ ស្តេចក្រុងពាលីចាកចេញពីទឹកដី ហើយបានពឹងឲ្យទេវតាប្រទូដឹមកទូលព្រះពុទ្ធថា បើពុទ្ធបរិស័ទធ្វើអ្វីក៏ដោយ ការងារអ្វី ពិធីមង្គលអ្វី និងពិធីបុណ្យផ្សេងៗ ត្រូវរំលឹកដល់ស្តេចក្រុងពាលីដែលជាម្ចាស់ទឹកដីផង ពេលនោះស្តេចក្រុងពាលីនឹងជួយឲ្យបានសេចក្តីសុខចម្រើន មានជោគជ័យសិរីសួស្តី សុភមង្គលដល់ម្ចាស់ពិធី។ ផ្ទុយទៅវិញ បើមិនបាននឹកដល់ខ្លួនទេ នោះខ្លួននឹងឡើងលើចុងឈើ ទម្លាក់ក្បាលចុះក្រោមឲ្យប្រាក់កស្លាប់ ហើយកាច់អ្នកទាំងនោះមិនខាន។

មូលនិធិខ្មែរសម្រាប់ការសិក្សា
CAMBODIAN EDUCATION EXCELLENCE FOUNDATION



www.elibraryofcambodia.org

*ឆយ យីហ៊ាង*

*ប្រែង ពិសិដ្ឋ　　　លេង ណៃគីម*

*ម៉ិល វាសនា　　　ភិនណារ៉ុង*

*ឈិត ភក្តី　　　ជា មុនីឫទ្ធិ　　　　　　　　　　ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ*

តាមការដំណាលនេះ ការធ្វើពិធីក្រុងពាលី គឺដើម្បីសុំសេចក្តីសុខសប្បាយពីស្តេចក្រុងពាលី។ ដោយហេតុនេះហើយ ទើបក្នុងពិធីកិច្ចផ្សេងៗរបស់ខ្មែរ តែតែងធ្វើពិធីសែនក្រុងពាលីនេះ ដោយការនិយាយពាក្យសុំទឹកសុំទីកន្លែង ដើម្បីសុំសេចក្តីសុខសប្បាយ សិរីសួស្តី។

ចំណែកលោក *ប៉ុក រ៉ាន់ធី*[៣] លើកឡើងថា រឿងព្រេងដែលទាក់ទងនឹងពិធីសែនក្រុងពាលីមានពីរគឺ រឿងព្រេងបែបព្រះពុទ្ធសាសនានិងបែបព្រហ្មញ្ញសាសនា។ លោកដំណាលរឿងទាំងនោះដូចតទៅ៖

រឿងព្រេងបែបព្រះពុទ្ធសាសនា មានការដំណាលដូចក្នុងសៀវភៅ *ប្រជុំរឿងព្រេងខ្មែរ ភាគ៩* ដែរ ប៉ុន្តែមានចំណុចខុសគ្នានូវចំណុចចុងក្រោយ នៅចំណុចចុងក្រោយបានដំណាលថា គំណជាតិមកស្តេចស្វាខ្មៅមានកំណើតជាព្រះពុទ្ធសព្វថ្ងៃ ស្តេងចស្វាសមានកំណើតជាស្តេចក្រុងពាលី។ ស្តេចក្រុងពាលី ឆ្លេចអស់ពីដើមកំណើតជាតិខ្លួនជាស្តេចស្វាសនឹងជាមិត្តតក្កិស្តេចស្វាខ្មៅ។ ពេលព្រះនិមន្តសាបព្រះធម៌ព្រះពុទ្ធសាសនា មានមនុស្សចូលមកសំណាក់ព្រះអង្គយ៉ាងសន្ធឹកសន្ធាប់ ណាស់។ ដឹងដំណឹងនេះ ស្តេចក្រុងពាលីក៏ច្រណែនហើយមកសុំធ្វើសង្គ្រាមជាមួយព្រះពុទ្ធ។ ប៉ុន្តែព្រះពុទ្ធាតបថា អ្នកជាមិត្តរបស់យើងពីអតីតជាតិហើយយើងសន្យាថានឹងមិនឈ្លោះប្រកែកគ្នាទេ។ តែស្តេចក្រុងពាលីមិនស្តាប់ ក៏ប្រកាសសឹកសង្គ្រាម។ ពេលនោះព្រះពុទ្ធថា បើព្រះអង្គចាញ់សុខចិត្តដាក់ខ្លួនបម្រើ ឯក្រុងពាលីថា សុខចិត្តនិរន្ទេសខ្លួនចេញៗពេលល្បែងសិល្បវិជ្ជា ព្រះពុទ្ធឈានតែមួយជំហានបានចម្ងាយរាប់រយយោជន៍។ ស្តេចក្រុងពាលីក៏សុំចាញ់ ហើយសុំទឹកដីព្រះពុទ្ធ ២ម៉ែត្រ ៤ជ្រុង ដើម្បីកប់ខ្លួនឯង។ ប៉ុន្តែស្តេចក្រុង

---

[៣]លោក *ប៉ុក រ៉ាន់ធី* អាយុ៥៨ឆ្នាំ ជាអនុប្រធាននាយកដ្ឋានសិល្បៈនាពយន្តផ្សព្វផ្សាយវប្បធម៌នៃក្រសួងវប្បធម៌និងសិល្បៈ (សម្ភាសន៍ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៣)



www.elibraryofcambodia.org

ពាលីបានផ្តាំថា បើធ្វើពិធីផ្សេងៗត្រូវរៀបចំសែនព្រេននឹកដល់យើងផង។ ពេលនោះព្រះពុទ្ធប្រកាសដល់អស់ប្រជាពលរដ្ឋ បើធ្វើពិធីអ្វីក៏ដោយត្រូវនឹកគុណដល់ស្តេចក្រុងពាលីផង ទោះបីព្រះអង្គមិននៅក៏ដោយ។

ហេតុនេះហើយ ទើបពេលធ្វើពិធីអ្វីមួយ គេតែងសែននឹកដល់ស្តេចក្រុងពាលី ហើយវាជាការដឹងគុណដល់ស្តេចក្រុងពាលីដែលជាម្ចាស់ទឹកម្ចាស់ដីផងដែរ។ ក្នុងការសែនព្រេននេះមាន នំ ផ្លែឈើ ទឹកឃ្មុំ គ្រឿងបង្អែម មានចេកជាដើម ដែលស្តេចក្រុងពាលីចូលចិត្ត។ ដង្វាយសម្រាប់ស្តេចក្រុងពាលីតាមបែបព្រះពុទ្ធសាសនា មិនមានដាក់ស្រា ក្បាលជ្រូក ឬមាន់ស្ងោរទេ គឺដាក់តែម្ហូបបួសដែលព្រះអងហាគសោយបាន។

ឯរឿងទាក់ទងនឹងព្រហ្មញ្ញសាសនា គឺទាក់ទងនឹងរឿង *រាមាយណ:* ។ កានោះក្រុងរាពណ៍ចាប់នាង *សីតា* យកទៅ។ ព្រះរាមនិងព្រះលក្ខណ៍បានកែនទ័ពទៅធ្វើសឹកសង្គ្រាមជាមួយក្រុងរាពណ៍ ដើម្បីរំដោះនាងសីតាមកវិញ។ ព្រះរាមនិងព្រះលក្ខណ៍បានជួបនឹងស្តេចក្រុងពាលី។ ដោយស្តេចក្រុងពាលីមានព្រះជ្រះថ្លាជាមួយព្រះរាម ក៏ព្រមដាក់ចិត្តកាយបម្រើព្រះអង្គធ្វើជាសេនាហែហម។ ស្តេចពាលីបាននាំទ័ពស្វាទាំងអស់ទៅជួយព្រះនាងសីតាជាមួយព្រះរាម។ ពេលធ្វើដំណើរដល់សមុទ្រមហាសាគរមួយឆ្លងទៅមិនរួច ស្តេចក្រុងពាលីបញ្ជាឲ្យទ័ពស្វាប្រមូលយកថ្មមកធ្វើស្ពានឆ្លងទៅនគរក្រុងរាពណ៍។ ទ័ពស្វាចាប់ធ្វើការតាំងពីពេលព្រលប់ រហូតដល់ម៉ោង៣ ឬ៤ទៀបភ្លឺ ទើបរួចរាល់អាចឆ្លងបាន។ ពេលទ័ពព្រះរាមឆ្លងចូលនគរទៀបភ្លឺនោះ ស្តេចក្រុងរាពណ៍ឥតដឹងខ្លួនទាន់ទេ។ បន្ទាប់មក ស្តេចពាលីក៏សុំបួសក្នុងព្រះពុទ្ធសាសនា តែព្រះអង្គថាមិនអាចពួសបានទេ ព្រោះស្តេចពាលីមានជាតិជាសត្វតិរិច្ឆាន។ ពេលនោះស្តេចពាលីថា បើមិនបានបួសក៏សុំតែសេចក្តីស្រឡាញ់ពីព្រះអង្គនិងប្រជារាស្ត្រផង មានន័យថា ពេលធ្វើពិធីអ្វីមួយ សុំឲ្យនឹកដល់រូបខ្ញុំផង។



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*

*ប្រែង ពិសិដ្ឋ* *លេង ណៃគីម*

*ម៉ិល វាសនា* *ភិនណារ៉ុង*

*ឈិត ភក្តី* *ជា មុនីឫទ្ធិ* *ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ*

លោក ប៉ុក វ៉ាន់ធី មានប្រសាសន៍ថា ពិធីក្រុងពាលីគេធ្វើនៅព្រឹកចាប់ពីពេលដែលព្រះសង្ឃលោកទទួលចង្ហាន់ឆ្ងាន (ពីព្រលឹមដល់ម៉ោង១២ថ្ងៃត្រង់) ។ បើតាមព្រហ្មញ្ញសាសនា គេធ្វើនៅពេលរសៀល។ ប៉ុន្តែយើងតែងធ្វើផ្សារភ្ជាប់គ្នា ចម្រុះគ្នា ឥតចោលមួយណាឡើយ។

## ២.៣.រឿងទាក់ទងនឹងពិធីបុកល័ក្ត

លោកអាចារ្យ សួន សុន[៤] បាននិយាយរៀបរាប់ថា កិច្ចពិធីបុកល័ក្ត ធ្វើធ្មេញ ធ្វើឡើងនៅពេលកូនស្រីចូលម្លប់ ពោលគឺពេលកូនស្រីពេញវ័យក្រមុំ និងគ្រប់ការ។ ការនៅក្មេង កូនស្រីមានភាពស្អាតស្អំនិងបរិសុទ្ធ តែនៅពេលពេញវ័យមានឈាមហូរចេញពីសាច់ ដែលបុរាណចាត់ថា ជាសេចក្តីមិនល្អ មានការប្រឡូកប្រឡាក់ មិនស្អាតស្អំ និងជាឧបទ្រពចង្រៃ។ ហេតុនេះ គេធ្វើពិធីបុកល័ក្តទទាក់ម្សៅនេះ ដើម្បីជម្រុះឧបទ្រពចង្រៃនិងភាពសៅហ្មងទាំងពួង។ ប៉ុន្តែក្រោយមក ដោយមិនមានពិធីចូលម្លប់សម្រាប់កូនស្រី ទើបគេធ្វើនៅពេលកូនស្រីរៀបអាពាហ៍ពិពាហ៍តែម្តង។

ទាក់ទងនឹងពិធីធ្មេញ សៀវភៅ *ប្រជុំរឿងព្រេងខ្មែរ ភាគ៩* [៥] សរសេរថា កាលនោះព្រះបាទអាទិត្យវង្សា ព្រះចៅក្រុងកម្ពុជាធិបតី ជាចៅទួតព្រះកេតុមាលា ទ្រង់សោយរាជ្យសម្បត្តិ ព្រះអគ្គទេពីជាកាកី ព្រះនាងមានគភ៌គ្រប់ទសមាសា ប្រសូត្រចេញមកជាពងដូចសត្វ។ ព្រះបាទអាទិត្យវង្សាតូចព្រះទ័យណាស់ ក៏ប្រើពេជ្រឲ្យយកពងនោះទៅកប់ក្នុងផ្នូកខ្សាច់ ទិសខាងលិចអង្គទាំងវាំងលាយប់ស្ងាត់។

ដោយខ្មាសគេពេក ព្រះរាជអគ្គមហេសីសុំព្រះស្វាមីត្រឡប់ទៅស្ថានទួដង្គនាគវិញ តែព្រះបាទអាទិត្យវង្សាមិនព្រម។ នៅ

---

[៤]លោកតាអាចារ្យ សួន សុន អាយុ៧២ឆ្នាំ នៅទួមិត្រពាំងក្រឡូងណា ឃុំក្បៀមក្សាន្ត ស្រុកខ្ទុត្តុង ខេត្តកំពង់ស្ពឺ(សម្ភាសន៍ថ្ងៃ ទី ២៩ ខែមីនា ឆ្នាំ ២០០៧)



www.elibraryofcambodia.org

ឆយ យីហ៊ាង

*ប្រែង ពិសិដ្ឋ* *លេង ណៃគីម*

*ម៉ិល វាសនា* *ភិនណារ៉ុង*

*ឈិត ភក្តី* *ជា មុនីឫទ្ធិ* *ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ*

[9] *ប្រជុំរឿងព្រេងខ្មែរ ភាគ៩.* ពុទ្ធសាសនាបណ្ឌិត.(បោះពុម្ពឡើងវិញដោយក្រសួងអប់រំយុវជន នឹងកីឡា). ភ្នំពេញ. ២០០៣. ទំព័រ ៣៤-៤០

រលាយប់ពេលព្រះនាងផ្ទុំលក់ បានប្រែរូបឯងៗទៅជានាគពេនទ្រេលពេញគ្រែៗ ឃើញដូច្នេះ ព្រះបាទអាទិត្យវង្សាភ័យច្រឡោត ស្ទុះរត់ប៉ះទង្គិចព្រះទ័ក្រទ្វារដួលបែកចេញឈាមៗ ព្រះអគ្គមហេសីធ្លាក់ឡើងស្ទុះទៅត្រកងនិងសួរមូលហេតុៗ ព្រះរាជាប្រាប់ពីមូលហេតុ ប៉ុន្តែ ព្រះអគ្គមហេសីបដិសេធថា ព្រះនាងមិនបានលេងខុសច្បាប់ទម្លាប់ទេ ពិតជាផ្ទុំលក់មិនដឹងខ្លួនឡើយៗ

ហោរាព្រឹទ្ធពិនិត្យលេខឃើញថា ហេតុទាំងនេះកើតដោយសារព្រះនាងព្រួយចិន្តា ផ្ទុំលក់ទៅមមើមមាយដរ័នខ្លឹកទៅកាន់ទីដទៃផ្សេងៗ ទើបក្លាយខ្លួនជានាគឯងៗទៅៗ ពេលនោះហោរាក្រាបទូលថា ត្រូវធ្វើពិធីព្រលឹង ហើយល្អងធូលីសុំធ្មេព្រះទន្ត សុំយកអាលម្តាយ(ហ្មពស់) មកឲ្យធ្វើថ្នាំមៀមឲ្យសាបពិសនាគ ទើបសម្តេចមហេសីលែងក្លាយខ្លួនជានាគ ដោយឯងៗទៀតៗ

ព្រះរាជានឹងព្រះអគ្គមហេសីយល់ព្រមៗ ស្តេចឲ្យរៀបពលិកាតាមហោរាបង្គាប់ រួចតាំងជញ្ជាត់ព្រលឹងតាមក្បួនបូរាណគ្រប់បរិបូណ៌ៗ ស្តេចឲ្យជាងតម្រឹមទន្តាស្រួចរបស់នាង ហើយយៅគ្រូអាលម្តាយមកផ្សំឱ្សថ សាច់ជ្រូក១មុខ លីក្តខ្មែរ១មុខ ផ្លែក្រូចសើច១មុខ ដុសលាយគ្នា ប្រសិទ្ធីដោយអាគម យកមកថ្វាយព្រះនាងមៀមបន្សាបពិសនាគ រួចស្រោបមាសដាំពេជ្រតាម ហោប្រាប់ៗ ព្រះនាងក៏បានស្បើយគ្រោះថ្នាក់ពីពេលនោះមក ហើយបានប្រសូតបុត្រមួយអង្គជា មនុស្សៗ

ដោយហេតុតាមរឿងនិទាននេះហើយ ទើបនៅក្នុងអាពាហ៍ពិពាហ៍ខ្មែរមានពិធីបុកលីក្តធ្វើធ្មេញ ដរាបមកៗ

## ២.៤.រឿងព្រះឥសូរនិងព្រះសុរិយារាជកុមារ(ទាក់ទងនឹងពិធីបង្វិលពពិល)

ព្រះឥសូរស្ថិតនៅភ្នំកៃលាស មានឫទ្ធិខ្លាំងពូកែ សូម្បីតែអង្គជាត(លឹង្គ)ព្រះអង្គនិងយោនីនាង ខ្មមាគោតរ៉តី ជាមហេសីដ៏ខ្លាំងពូកែស័ក្តសិទ្ធណាស់ៗ ថ្ងៃមួយ ព្រះឥសូរប្រោសមេត្តាព្រមទទួល បង្រៀនព្រះជ័យសុរិយារាជកុមារនៅឯនគរកែកេតជម្ពូ នាជម្ពូទ្វីប ដែលត្រាច់ស្វែងរករៀន សិល្ប៍សា ស្រ្តៗ ព្រះទ្រង់ស្តោះទឹកព្រះខ្ញីស្ត(ទឹកមាត់) ដាក់ព្រះខ្ញីស្តរបស់ព្រះរាជកុមារឲ្យមាន



www.elibraryofcambodia.org

កម្លាំងដូចដំរីសារ។ រៀនចេះសព្វគ្រប់ហើយ ព្រះរាជកុមារបានក្រាបបង្គំសុំពរជ័យមង្គលសម្រាប់មនុស្សជាតិឲ្យមាន សិរីសួស្តីសម្បូរណ៌សប្បាយ។ ព្រះឥសូរបាបប្រសិទ្ធីដីខ្សាច់ពេជ្រពីន្ទុចក្រវាឡ ជាស្លឹកពោធិ៍មាស (តំណាងយោនីនាងខ្មា) និងប្រសិទ្ធីថ្មពេជ្រពីន្ទុហិមាល័យ ជាទៀនមាស (តំណាងអង្គជាតព្រះអង្គ) ហើយសន្មត់ឈ្មោះថា "ពរពីរតន៍" ប្រទានដល់ដល់ព្រះរាជសុរិយា យកទៅសម្រាប់មនុស្សជាតិបង្វិល ជុំវិញគូស្វាមីភរិយាថ្មី ហើយបក់ផ្សែងចូលក្នុងមាត់ដើម្បីឲ្យមានកម្លាំងពលំខ្លាំងក្លា ហើយបុត្រធីតា ដែលកើតមានបញ្ញាឆ្លាតវាងវៃ។

តំណាតមកគេហៅថា ពពិល។ៗ ដោយអស់ទៀនមង្គលនេះ អ្នកស្រុកបានយកប្រាក់ សំរឹទ្ធិ ទង់ដែង ស្ពាន់ ឬដែកធ្វើជាស្លឹកពោធិ៍ ហើយយក្រមួនលញ់ធ្វើជាទៀន។ តពីនោះមក ក៏មានពិធី បង្វិលពពិលក្នុងពិធីអាពាហ៍ពិពាហ៍ខ្មែរជាប់ជាប្រពៃណីរហូតដល់សព្វថ្ងៃនេះ ៦។

លោក *ប៉ុក វ៉ាន់ធី* បានពន្យល់ថា គឺ *ពពីរ* មិនមែន *ពពិល* ទេ។ វាជាពពីរដែលព្រះឥសូរនិង ខ្មាទោតវតី ជាភរិយាផ្តល់ដល់រាជកុមារ។ ពរទី១ ព្រះរាជកុមារកុមារមានមាត់ទិព្វ ប្រាថ្នាអ្វីក៏បាន សម្រេច។ ពរទី២ ឲ្យរាជកុមារមានកម្លាំងពលំ បញ្ញាស្មារតីឈ្នះអស់ទុក្ខទ័យ។ វាជាពិធីតាមបែបព្រហ្ម ញ្ញសាសនា។ ក្នុងអាពាហ៍ពិពាហ៍ខ្មែរ កូនប្រុសកូនស្រីហិតផ្សែងពពិល ដើម្បីឲ្យមានកម្លាំង បញ្ញាឆ្លាតវៃនិងប្រាថ្នាអ្វីបានដូចបំណង។

លោកតា សួន សុន បាននិទានរឿងទាក់ទងនឹងការបង្វិលពពិលថា៖

កាលណោះ *មង្គលៈ* បានសកំណើតជាកូនរបស់ព្រាហ៍ដ៏ក្រីក្រម្នាក់ដែលចុះកំណើតជាស្តេច។ *មង្គលៈ* បានទៅធ្វើការងារបម្រើសេដ្ឋីដើម្បីចិញ្ចឹមជីវិត។ នៅចូលវស្សា សេដ្ឋីនិងអ្នកស្រុកទួមិមានលុយ ទិញទៀនដង្ហែចូលវត្ត ឬទិញទៀនបម្រើក្នុងក្នុងពិធីផ្សេង។ៗ ដោយគ្មានលុយទិញទៀននឹងគេ *មង្គលៈ* បានទៅរកជ័រឈើមកប្រឡាក់នឹងសំឡី ហើយរុំពីទួខ្លួនធ្វើជាទៀនដង្ហែចូលវត្តព្រះ



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*
*ប៉ែង ពិសិដ្ឋ*	*លេង ណៃគីម*
*ម៉ិល វាសនា*	*ភិនណារ៉ុង*
*ឈិត ភក្តី*	*ជា មុនីឫទ្ធិ*	*ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ*

ជេតពន ដោយ ប្រាថ្នាសុំឲ្យងនាគតនៃជាតិខ្លួនកើតមកមានបញ្ញាស្មារតីភ្លឺថ្លា ឈ្លាសវៃ ដ្បិតជាតិនេះខ្លួនល្ងិតល្ងង់ មិនដូចអ្នកផងទាំងពួង។ *មង្គល:* បានរំខ្លួនជាទៀនប្រគេនព្រះពុទ្ធសាសនា ប៉ុន្តែភ្លើងមិនឆេះខ្លួនគេ ឡើយ។

---

[៦]ចាប ពិន (ឧត្តមប្រឹជា)ធៈ ក្បួនតម្រង់ការអាពាហ៍ពិពាហ៍ពិពាហ៍, បណ្ណាគារ សួន សេងហួត ភ្នំពេញ, ព.ស២៥០៨, គ.ស១៩៦៥, ទំព័រ ៦៣

ហេតុនេះ គេធ្វើពិធីបង្វិលពពិលក្នុងអាពាហ៍ពិពាហ៍ខ្មែរដើម្បីឲ្យកូនចៅកើតមកមានបញ្ញា ស្មារតីវៃឆ្លាត មិនល្ងិតល្ងង់ ពោលគឺពិធីនេះតំណាងឲ្យបញ្ញា។

## ២.៥.រឿងព្រះថោងនិងនាងនាគ(ទាក់ទងនឹងពិធីគោងស្បៃ)

មានរឿងដំណាលថា កាលនោះស្តេច *ភុជង្គនាគ* និងអគ្គមហេសី*ធាការី* ព្រមទាំងនាម៉ឺនមន្ត្រី នៃស្ថានភុជង្គនាគបានរៀបដង្ហែបុត្រីនាង *ទាវឌី* [៧] និងបណ្ណាការជាច្រើនមកអភិសេកឲ្យជាអគ្គមហេសី ស្តេច *ព្រះថោង*។ ស្តេចភុជង្គនាគបានបង្គាប់សេនានាគរាជឲ្យជប់បង្ហូរទឹកឲ្យគោក ជាដែនដីធំទូ លាយ និងនិម្មិតជារាជវាំង ប្រាសាទ ឥតខ្វះចន្លោះ។ មង្គលការប្រព្រឹត្តទៅ ៧យប់ ៧ថ្ងៃ។

លុះរួចស្រេចអភិសេកនៅកោះគោកធ្លកហើយ ស្តេចភុជង្គនាគតម្រូវឲ្យទៅរៀបអភិសេកនៅឯ ស្ថានភុជង្គនាគម្តងទៀត ដើម្បីឲ្យប្រជារាស្ត្រនៅទីនោះបានស្គាល់ផងនិងថ្វាយនាមនគរ នាមបុត្រទាំង ពីរជាថ្មីផង។



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*

*ប្រែង ពិសិដ្ឋ លេង ណៃគីម*

*ម៉ិល វាសនា ភិនណារ៉ុង*

*ឈិត ភក្តី ជា មុនីឫទ្ធិ* *ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ*

នាង ធាវ័តី យល់ថា ព្រះបិតានឹងសម្លាប់ស្វាមីខ្លួន នាងបានឲ្យស្តេចព្រះថោងចាប់តោងកន្ទុង របស់នាងឲ្យជាប់ជិត កុំឲ្យទឹកប្រសព្វបិទផ្លូវស្តេចព្រះថោងនៅច្រកទ្វារនោះមិនខាន។ នាងបានប្តូរឲ្យ ព្រះថោងស្លៀកសំពត់ដើម្បីបំភាន់អ្នកយាមទ្វារ។ ដោយមើលឃើញសុទ្ធតែស្រី មានក្រឡាជានាគ មិនចាប់អារម្មណ៍ ពេជ្ឈឃាតក៏ច្រឡំ មិនបានសម្លាប់ស្តេចព្រះថោងទៅ។

ស្តេចព្រះថោងបានទៅដល់ស្ថានតុជង្គនាគ ពេលនោះស្តេចតុជង្គនាគ ក៏ជឿថា ព្រះថោងមាន បុណ្យមែន ហើយក៏ជួបជុំអស់ពពួកនាគនឹងយកគ្រឿងប្រដាប់នាគមកឲ្យស្តេចព្រះថោងស្លៀកពាក់ តាមនាគ រៀបអភិសេកយ៉ាងឱ្យឡារីក។ ស្តេចតុជង្គនាគបានថ្វាយព្រះនាមព្រះថោងជាព្រះបាទ កុមេរាជ ធាវ័ដីចានាង ទាវ័ធីតា កោះគោកធ្លកជា ក្រុងកម្ពុជាធិបតី ដែលស្ថិតក្នុងការទំនុកបម្រុងនៃ នគរតុជង្គនាគ។

---

៥នាងទាវ័ដ្តី (នាងទាវ័តី ឬនាងទាវ័ដ្តី) តាមសៀវភៅណា *ប្រជុំរឿងព្រេងខ្មែរ ភាគ៩.* ពុទ្ធសាសនាបណ្ឌិត.(បោះពុម្ពឡើងវិញដោយក្រសួងអប់រំ យុវជន នឹងកីឡា). ភ្នំពេញ. ២០០៣. ទំព័រ ៥៧

ដោយហេតុដូច្នេះហើយ ទើបក្នុងអាពាហ៍ពិពាហ៍ខ្មែរមានកិច្ចពិធីកូនប្រុសតោងជាយស្បៃកូនស្រីចូលបន្ទប់។ ពិធីនេះតម្រូវឲ្យ កូនប្រុសស្លៀកហូលមានក្រឡាគោមដូចនាគ ក្នុងន័យបំភាន់ពេជ្ឈឃាតយាមទ្វារស្តេចតុជង្គនាគមិន ឲ្យសម្លាប់។ ខ្លឹមសារមួយទៀត ការស្លៀកសំពត់នេះចកិច្ចសញ្ញានៃការផ្សំដំណេក (ការចូលរួងនាគ)។

## ២.៦.រឿងក្មេងពីរនាក់(ទាក់ទងនឹងកច្ចពិធីសាកល្បងនិងសែនព្រេនលើសសរកន្លោង)

រឿងនេះដំណាលថា មានបុរសពីរនាក់ជាក្លើនឹងគ្នា។ ក្លើម្នាក់ត្រូវការប្រពន្ធ តែខ្លួនខ្វះក្រមួនឃ្មុំ ធ្វើទៀនពេលា។ ពេលនោះ គេក៏និយាយនឹងក្លើដែលគ្មានប្រពន្ធឲ្យជួយទៅរកសំណុសឃ្មុំជាគ្នា។ លុះដើរទៅដល់ពាក់កណ្តាលព្រៃ ឃើញដើមឈើធំខ្ពស់ ហើយរបូតឈ្មូតក្បាលមានឃ្មុំច្រើន បុរសត្រូវ រៀបអាពាហ៍ពិពាហ៍ ក៏កាប់បង្កោងពាក់តោងឡើងទៅដល់ចុងឈើ។ បុរសក្លើដែលចាំ



www.elibraryofcambodia.org

នៅគល់ឈើ នោះ ក៏រុះបង្អោងចោល យកបន្លាស្រះគល់ឈើជាប់មិនឲ្យចុះរួច។ បន្ទាប់មក បុរសនោះមកប្រាប់ឪពុក ម្ដាយក្មេីដែលត្រូវរៀបអាពាហ៍ពិពាហ៍វិញថា ដ្បិតមានសត្វវាខាំពាំនាំយក្លើទៅ ទោះខំដើបម្រាសក៏ពុំរួច ហើយមុខជាស្លាប់ជាមិនខាន។ គេថាក្លើនោះផ្ដាំឲ្យរូបគេមកប្រាប់ឪពុកម្ដាយខ្លួន ដើម្បីសំពះការយក ប្រពន្ធរបស់ខ្លួនដែលនឹងរៀបអាពាហ៍ពិពាហ៍នោះចុះ ដោយខ្លួននឹងពុំបានរស់មកវិញទេ។

ដោយយល់ឃើញថា បុរសនោះជាគូនឹងនាងជាប្រពន្ធ ហើយបុរសក្លើចិត្តវៀចបែរលួចប្រពន្ធ គេដូច្នេះ ទេវតាមួយអង្គដែលថែរក្សាដើមឈើនោះបានក្រឡាខ្លួនជាខ្លាឃ្មុំ បញ្ឆួលចិត្តបុរសឲ្យគោង កន្ទុយដើម្បីឲ្យបុរសរួចរស់បានទៅការប្រពន្ធ។ ដោយឃើញខ្លាឃ្មុំដូចនេះ បុរសនោះគិតក្នុងចិតថា បើនឹងស្លាប់ឬរស់ក៏ស្លាប់ចុះក្នុងពេលនេះ។ បម្រុងចាប់គោងកន្ទុយខ្លាឃ្មុំ ខ្លាឃ្មុំក៏មកជិតឲ្យបុរសនោះ ចាប់គោងយ៉ាងស្រួល។ ខ្លាឃ្មុំបាននាំបុរសនោះចុះមកដល់ដីហើយរលាយបាត់ទៅ ឃើញតាចាស់ម្នាក់ មកប្រាប់ថា បើបុរសឯងមានប្រពន្ធ ពេលរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើកន្ទោងបួនជ្រុងមួយដាក់ចំណី បង្អែម ទឹកឃ្មុំដាក់លើធ្នឹម នឹកគុណដល់ទេវតាដែលនាំពីចុងឈើមកដល់ដី ទើបរៀបអាពាហ៍ពិពាហ៍ បានសេចក្ដីសប្បាយនិងអាយុវែង។ ស្ដាប់ហើយ បុរសនោះសម្ដីម្នាមស្រូតមកទាន់ពេលកំពង់តែចង់ ដៃ។

បុរសនោះបានយកដាវកាប់បុរសក្លើលួចប្រពន្ធខ្លួន ដែលកំពុងតែផ្ទឹមចងដៃស្លាប់ទៅ។ ឈាម ប្រឡាក់កន្ទេល ខ្នើយដែលសំពះផ្ទឹម ហើយអស់មេបាស្រវាចាប់កន្ទេលខ្នើយចោលអស់ទៅ។ ខ្មោច ត្រូវទាត់ចោលទៅដី រើស្បូវដំបូលមាងបួនកន្ទបគ្របខ្មោចបុរសនោះ រួចវិញឡើងមកយកទាំងពន្លឺមូល ដោតជើងជណ្ដើរ ហើយឲ្យអាចារ្យសូត្ររម្ងាប់។ បន្ទាប់មកកាត់ចំណងដៃពីកូនស្រីដែលចងដៃនឹង បុរសដែលស្លាប់នោះចេញ ហើយយកកន្ទេលថ្មី ខ្នើយថ្មីមករៀបក្រាលឲ្យបុរសប្ដីសាមីខ្លួនស្រីសំពះ យកគ្នាជាប្ដីប្រពន្ធតទៅ។



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*
*ប្រែង ពិសិដ្ឋ*　　*លេង ណៃគីម*
*ម៉ិល វាសនា*　　*ភិនណារ៉ុង*
*ឈិត ភក្តី*　　*ជា មុនីឫទ្ធិ*　　*ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ*

ទាក់ទងនឹងរឿងខាងលើនេះហើយ ទើបក្នុងពិធីកិច្ចមង្គលក្នុងអាពាហ៍ពិពាហ៍ខ្មែរមានការ ដោតផ្កាស្លាថ្មី មានអាចារ្យម្នាក់កាត់ចំណងដៃ មានពិធីសាលកន្ទេល មានដាវមួយ មានពន្លមួលដោត ជើងជណ្តើរនិងកន្ទោងដាក់លើផ្ទឹម(សែនសសរកន្លោង) រហូតមក។

ទាក់ទងនឹងការសែនសសរកន្លោង លើកកន្ទោងដាក់លើផ្ទឹម នេះដែលលោកអាចារ្យ សួន សុន មានប្រសាសន៍ថា គឺទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ជាលើនិងក្រឹស្នា។ ដោយសារជាលើនិងក្រឹស្នា ជាបងប្អូនបង្កើតនឹងគ្នា ទើបអ្នកឆ្លងច្រៀងរាំខ្ទំបអង្គរសសរ យកជើងក្បៀសសរកន្លោង ហើយនូវ លើកកន្ទោងដាក់លើផ្ទឹម អ្នកចម្រៀងប្រុសសួរអ្នកចម្រៀងស្រីថា *តើបងដាក់ត្រូវហើយ ឬនៅ?* នៅទេ បង (ស្រីឆ្លើយ)។ សួរបែបនេះរហូតលើកទីបី ទើបឆ្លើយថា *ត្រូវហើយបង*។ អញ្ចឹងបងរុញដាក់ហើយ ប្រុសឆ្លើយតបជាកិច្ចបង្ហើយពិធី។ ការធ្វើបែបនេះ ដើម្បីជំរុញកាមតណ្ហាឲ្យអ្នកទាំងពីរចេះស្រឡាញ់គ្នា ជាប្តីប្រពន្ធ។ ហេតុនេះហើយទើបកិច្ចពិធីនេះមានរហូតដល់សព្វថ្ងៃ។

## ២.៧.រឿងជ័យនិងសូស្តី(កូននារីកំសត់)

កាលពីព្រេងនាយមានក្មេងស្រីម្នាក់ក្រកំសត់ អត់ឪពុក មានតែម្តាយ។ សម័យពេលមួយ ស្រុកជួបទុរ្ភិក្ស អត់ឬាយអត់ទាំងនគរ ព្រមទាំងរាំងគ្មានភ្លៀងសោះ។ អស់រយៈពេល១២ឆ្នាំ នាងដើរ ជីកមើមឈើ មើមដំឡូងយកមកអាស្រ័យជំនួសបាយជារៀងរាល់ថ្ងៃ។ យប់មួយ នាងយល់សុបិន ឃើញដូចកោសិយ(ព្រះឥន្ទ្រ) យកគជ់មានរស្មីសម្បុរល្អមកឲ្យនាង ហើយកោសិយប្រាប់ថា គជ់នេះ ជាគជ់ស្តេចដំរីសឲ្យរក្សាទុកឲ្យបានល្អ យូរលង់ទៅនឹងបានជាអ្នកធំ ហើយកោសិយក៏បាត់ទៅ។ លុះព្រឹកឡើង នាងក៏រៀបចំម្ហូមអាហារ សំណុំទឹក ចំពង់សម្រាប់ទៅព្រៃដូចសព្វដង។



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*

*ប្រែង ពិសិដ្ឋ*　　*លេង ណៃគីម*

*ម៉ិល វាសនា*　　*ភិនណារ៉ុង*

*ឈិត ភក្តី*　　*ជា មុនីឫទ្ធិ*　　*ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ*

ជួនថ្ងៃមួយ ក្មេងស្រីនោះក្មេងស្រីនោះក៏ទៅរកជីកដំឡូងនឹងគេៗ ទៅដល់កណ្តាលព្រៃជ្រៅ គ្មានអ្នកស្រុករស់នៅទេៗ ជួនជាមេឃងងឹត មានផ្គរលាន់ហាក់បម្រុងនឹងធ្លាក់ភ្លៀង ចាស់ៗដែលទៅដែលទៅជាមួយនាងក៏និយាយឡើងថា  យើងចាក់បំពង់នោះទៅដើម្បីចាំដងយកទឹកភ្លៀងៗ បន្ទាប់មកមេ យក៏ស្រឡេះ គ្មានភ្លៀងសោះ នាងហូបប្លាយរួចអត់ទឹកផឹក សុំគេផឹកក៏គេមិនឲ្យ នាងក៏ដើរទៅព្រៃរក ទឹកតែម្នាក់ឯងតាមគន្លងដំរីៗ ឃើញទឹកដក់នៅកន្លែងស្នាមដានដំរីស្មានថាជាទឹកល្អ នាងក៏ខ្ញុំនផឹក រួចមកទើបនាងដឹងថា ទឹកនោះជាទឹកនោមដំរីៗ ពេលត្រឡប់មកកន្លែងដើមវិញ នាងរកអ្នកទៅជាមួយ មិនឃើញ ហើយក៏វិលមកកាន់ទីលំនៅរបស់ខ្លួនវិញៗ

បន្ទាប់ពីនាងផឹកទឹកនោមដំរីមក នាងក៏មានផ្ទៃពោះៗ លុះគ្រប់ខែ នាងប្រសូតបានកូនប្រុស មួយ ដែលដាក់ឈ្មោះថា *ជ័យ* ក្រោយមកនាងមានប្តីឈ្មោះ សុខ ហើយមានកូនប្រុសមួយទៀតឈ្មោះ *សួស្តី*ៗ ក្រោយមកឪពុកក៏ស្លាប់ចោលទៅ ទុកឲ្យ *ជ័យ* និង*សួស្តី* នៅកំព្រាជាមួយម្តាយៗ

EDUCATION
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION

គ្រានោះ ស្តេចនគរទ្រង់ចូលទិវង្គតៗ ដោយមិនមានព្រះរាជបុត្រស្នងរាជបន្ត អ្នកនគរបាននាំគ្នា ធ្វើពិធីផ្សងដំរី ដើម្បីស្វែងរកអ្នកមានបុណ្យបារមីមកគ្រងរាជជាស្តេចៗ ដំរីសនោះដើរតម្រង់មកដល់ផ្ទះ *ជ័យ សួស្តី* ហើយក្រាបសំពះនៅត្រង់ចុងជើង*ជ័យ* និង*សួស្តី*ៗ អស់អ្នកនគរដែលគ្រឿងសម្រាប់រាជ្យ ដើរតាមដំរីឃើញដូច្នោះ ក៏អញ្ជើញ *ជ័យ សួស្តី* ឲ្យឡើងជិះលើរៀងដំរីត្អមង្គលដើម្បីដង្ហែចូលព្រះ នគរ ហើយអភិសេក *ជ័យ* ជាស្តេចគ្រងរាជ *សួស្តី* ជាប្អូនជាឧបរាជៗ ក្នុងពេលអភិសេកនោះ គេស្រែកប្រកាសថា ជ័យហោង សួស្តីហោង មែនហោងគ្រប់វារៈបីដងទើបស្រាចទឹកៗ ក្រោយអ្នកស្រុកបាន ឃើញក្បួនដង្ហែ *ជ័យ* និង*សួស្តី* ក៏និយាយគ្នាថា មួយនោះដូចជា *ជ័យ* មួយនោះដូចជា *សួស្តី* ៗ ម្នាក់ទៀតឆ្លើយឡើងថា ជ័យហើយថាមិនជ័យ ម្នាក់ទៀតឆ្លើយឡើងថា សួស្តីថាមិនសួស្តី មែនហោងៗ



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*

*ប្រែង ពិសិដ្ឋ* *លេង ណៃគីម*

*ម៉ិល វាសនា* *ភិនណារ៉ុង*

*ឈិត ភក្តី* *ជា មុនីឫទ្ធិ* *ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ*

តណាតមកក៏កើតមានការស្រែកពាក្យ ជ័យហោង សួស្តីហោង នៅក្នុងពិធីអាពាហ៍ពិពាហ៍ខ្មែរ រហូតសព្វថ្ងៃនេះ ដ្បិត *ជ័យ សួស្តី* ជាអ្នកមានសំណាងបានធ្វើជាស្តេច ហើយពាក្យថា ជ័យ សួស្តី ជា ពាក្យមង្គលផងដែរ។

## ២.៨.រឿងអ្នករៀនសិល្បិ៍សាស្ត្រ៤នាក់(ទាក់ទងនឹងផ្កាស្លាបី)

កាលនោះ មានបុរស៤នាក់ ទៅរៀនសិល្បិ៍សាស្ត្រជាមួយគ្នា។ ម្នាក់រៀនទស្សន៍ទាយ ម្នាក់រៀនបាញ់ធ្នូ ស្នា ម្នាក់រៀនមុជទឹក ម្នាក់រៀនប្រោសជីវិត។ លុះរៀនចេះសព្វគ្រប់ហើយ ក៏នាំគ្នាសុំក្រាបបង្គំ លាលោកអាចារ្យព្រាហ្មណ៍វិលត្រឡប់មកលំនៅស្ថានខ្លួនវិញ។ លុះមកដល់ស្ទឹងមួយ បុរសចេះទស្សន៍ ទាយ បានទាយថា ថ្ងៃនេះនឹងមានសត្វ *វាយោទក្យ* នាំស្រីក្រមុំម្នាក់មក នឹងបានជាភរិយាយើង។

ថ្លែងពីសត្វ *វាយោទក្យ* ថ្ងៃនោះឯងវាឆាបយកនាង *ក្រមុំខេមរី* ជាបុត្រស្តេច ដែលកំពុង ក្រសាលក្នុងទឹកស្រះបានហើយក៏ហើរទៅ។ លុះមកដល់ស្ទឹងដែលបុរសទាំង៤ឈប់សម្រាក បុរសចេះបាញ់ធ្នូ ក៏ទាញធ្នូបាញ់ទៅសត្វនោះ។ បន្ទាប់មក សត្វនោះក៏ទម្លាក់នាង *ខេមរី* ទៅក្នុងទឹក។ ឃើញដូច្នេះ អ្នកចេះមុជក៏មុជទៅស្រង់នាងឡើងមក តែនាងបានស្លាប់ទៅហើយ ទើបអ្នកចេះប្រោស បានប្រោសនាងឲ្យរស់រានមានជីវិតឡើងវិញ។

បុរសទាំង៤នាក់ឃើញនាង ខេមរី មានរូបឆោមពណ៌ល្អ ក៏ចង់បានធ្វើជាភរិយារៀងៗខ្លួន តែមិនសម្រេចបានទៅលើរូបនរណាឡើយ។ រឿងនេះក៏កើតអង្គសេចក្តីដល់ព្រះពោធិ៍សត្វ។ ព្រះអង្គបានកាត់សេចក្តីថា នាងត្រូវបានជាភរិយាបុរសចេះមុជទឹក ព្រោះរូបគេបានចាប់កៀកបីពរផ្ទាល់លើរូប កាយរបស់នាងនោះរួចមុនគេទៅហើយ (ធម្មតាស្ត្រីមានភរិយាបថល្អ មិនមានបុរសណាប៉ះពាល់ដល់ ខ្លួននាងមួយជាពីរឡើយ)។ ចំណែកបុរសចេះទាយ លោកទុកជាបិតា បុរសចេះប្រោស លោកទុកជា មាតា ហើយបុរសចេះបាញ់ធ្នូ ទុកដូចជារៀមច្បងរបស់នាង។ គ្រានោះព្រះបរមពោធិ៍សត្វគម្រូវឲ្យបុរស មុជទឹកនោះ ដោតផ្កាស្លាព្រះពរ



www.elibraryofcambodia.org

បី។ ផ្កាផ្លាច្បង ដោតស្លា២១ ម្លូ២១ ផ្កា១៩ (ជាការតបគុណបិតា) ផ្កាស្លាបន្ទាប់ ដោតស្លា១២ បុរសចេះឬាញ់ធ្នូ ទុកដូចជាអរម្យចង្បងរបស់នាង។

គ្រានោះព្រះបរមពោធិ៍សត្វតម្រូវឲ្យបុរសមុជទឹកនោះ ដោតផ្កាស្លាព្រះពរបី។ ផ្កាស្លាច្បង ដោតស្លា២១ ម្លូ១២ ផ្កា១៩ (ជាការតបគុណបិតា) ផ្កាស្លាបន្ទាប់ ដោតស្លា១២ ម្លូ២១ ផ្កា៩(ជាការតបគុណមា តា) ផ្កាស្លាពៅ ដោតស្លា៧ ម្លូ៧ ផ្កា៩(ជាការតបគុណអរម្យចង្បង)[៨] ។

ដ៏រាបមរៀងមក ក៏កើតមានផ្កាស្លាបីក្នុងអាពាហ៍ពិពាហ៍ខ្មែរ ដើម្បីជាការតបស្នងសងគុណដល់បិ តា មាតានិងអរម្យចង្បង។

## ២.៩.រឿងទាក់ទងនឹងផ្លែឈើ៣៦មុខ

មានការដំណាលថា កាលព្រះរាមនាំនាងសីតានិងពួកពានរមកដល់ព្រះបន្លាក្នុងព្រៃហិមពាន្តក៏ ឈប់នៅទីនោះ។ គ្រានោះមានឥសីមួយអង្គមកអភិសេកឲ្យពរព្រះរាមនិងនាងសីតា។ អស់ពួកពានរ ទាំងឡាយបបួលគ្នាទៅរកបេះផ្លែឈើទុំ ខ្ចី តាមនិស្ស័យសត្វមកប្រគេនឥសី។ ហេតុនេះហើយបានជា មានការរៀបរៀងផ្លែឈើនៅក្នុងអាពាហ៍ពិពាហ៍ខ្មែរជាទម្លាប់មកដល់បច្ចុប្បន្ន។

ផ្លែឈើមាន៣៦មុខ គឺចេក១២មុខ ស្វាយ១២មុខ ល្មុត មង្ឃុត សេតា១២មុខ។ ក្នុង១មុខ មាន ១ស្លឹក ៥ផ្លូន។

លោក ប៉ុក វ៉ាន់ធី [៩] បានដំណាលថា កាលនោះមនុស្សមិនទាន់មានលក្ខណៈពេញលេញនៅ ឡើយ ពោលគឺមានលក្ខណៈជាមនុស្សស្វា។ ប៉ុន្តែគេមានវិចារណញ្ញាណ ចេះពិចារណារកហេតុផល ដឹងខុសត្រូវហើយ។ នៅពេលរៀបចំអាពាហ៍ពិពាហ៍ កូនស្រីក៏មានជំងឺ មិនឃ្លានអ្វី ទទួលទានក៏មិន បាន។ ថ្ងៃមួយ កូនស្រីនោះនឹកចង់ទទួលទានផ្លែឈើដែលមានរសផ្អែម ឬចត់ជូរ។ ពួកនាំគ្នាទៅបេះ ផ្លែឈើឲ្យកូនស្រីទទួលទាន។ ទទួលទានរួច កូនស្រីមានកម្លាំងចេះឃ្លានទឹកនឹកចំណី។ ពេលគេពិចារ ណារក



www.elibraryofcambodia.org

ឆយ ឃីហ៊ាង

ប្រៃង ពិសិដ្ឋ លេង ណៃគីម

ម៉ិល វាសនា ភិនណារ៉ុង

ឈិត ភក្តី ជា មុនីឫទ្ធិ ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ

---

[1]លី ស៊ុំវ: ទម្រង់ការ *ព្រះជ័យចេស្តា*, ២០០៩, ទំព័រ ៩

[2]លោក *ប៉ុក វ៉ាន់ធី* អាយុ៥៨ឆ្នាំ ជាអនុប្រធាននាយកដ្ឋានសិល្បៈតាពយន្តផ្សព្វផ្សាយវប្បធម៌នៃក្រសួងវប្បធម៌និងសិល្បៈ (សម្ភាសន៍ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣)

មិនឃើញពីមូលហេតុនាំឲ្យកូនស្រីបានស្បើយជម្ងឺ គេក៏នាំគ្នារាប់ផ្លែឈើនោះ ឃើញមាន៣៦ មុខ (ផ្លែឈើដែលកូនស្រីនោះទទួលទាន) ។ ថ្ងៃក្រោយមក ដើម្បីសិរីសួស្តីក្នុងអាពាហ៍ពិពាហ៍ គេនាំគ្នា រៀបផ្លែឈើឲ្យគ្រប់៣៦មុខៗ ទាំងសាមីខ្លួន ទាំងភ្ញៀវកិត្តិយសនាំគ្នាទទួលទានផ្លែឈើទាំងនោះ ដោយគេជឿថា វាជួយឲ្យជាសះស្បើយជំងឺនិងចាកផុតពីសត្រូវទាំងពួងៗ

គេធ្វើពិធីរៀបរៀងផ្លែឈើដោយការចងរណោងរណោាង ហើយឲ្យកូនស្រីលោកបេះដើម្បីយក ទៅប្លាចចែកជូនភ្ញៀវដែលអញ្ជើញចូលរួមៗ ពីដើមគេធ្វើនៅយាម២,៣ឬ៤(ប្រហែលម៉ោង១២យប់ រហូតដល់ភ្លឺតែម្តង)ៗ ហេតុនេះផ្លែឈើ៣៦មុខ ជានិមិត្តសញ្ញានៃសេចក្តីសុខសិរីសួស្តីៗ

## ២.១០ រឿងចៅប្រម៉ាញ់ជងស៊ឺងនិងនាងត្រចើលដោះក្រាល

សៀវភៅរបស់ លី ស៊ុំវ: "ទម្រង់ការ *ព្រះជ័យចេស្តា*" សសរថា កាលនោះតាដុំងនិងយាយជ័យ មានទំនាក់ទំនងចូលគាល់ស្តេចសម័យនោះរឿយៗ គឺព្រះនាមព្រះបាទ *បទុមរាជ*ៗ *នាងទែន* រស់នៅ ខេត្តត្រាំងបានមកពឹងបុណ្យតាដុំង យាយជ័យ អំពីបញ្ហាដីស្រែ ព្រោះគាត់មានទំនាក់ទំនងជាមួយនឹង ស្តេចៗ តាដុំងបានជួយនាងទែនឲ្យឈ្នះលើបញ្ហាដីស្រែៗ



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*

*ថៃប្រែង ពិសិដ្ឋ*　　*លេង ណៃគីម*

*ម៉ិល វាសនា*　　*ភិនណារ៉ុង*

*ឈិត ភក្តី*　　*ជា មុនីឫទ្ធិ*　　*ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ*

តាដុង យាយជ័យ មានកូនស្រីម្នាក់ឈ្មោះនាង ត្រចើលដោះក្រាល មានរូបសម្បត្តិល្អប្រពៃ លើសអ្នកផងទាំងពួង។ គាត់បានផ្ញើរកូនស្រីឲ្យរស់នៅជាមួយនាងទែន ដើម្បីលាក់ពីស្តេច ដ្បិតនាងមានរូបមានរូបល្អ។

ថ្ងៃងពីស្តេចមួយអង្គ ព្រះនាមខូទេយ្យរាជ សោយរាជនៅនគររាជ យកប្រពន្ធនាគ ហើយប្រ សូតបុត្រជាស៊ុត។ ព្រះអង្គយល់ថា ជាកំណើតខូត្បាត ក៏បញ្ជាឲ្យគេយកទៅចោល។ ព្រានព្រៃម្នាក់ ឈ្មោះ *តង់* នៅពេលស្វែងរកបរបាញ់ម្រឹគក៏បានប្រទះស៊ុតចម្លែកនោះ។ ព្រាននោះបានរើសស៊ុតនោះ មករក្សាទុករង់ចាំពេលវាញាស់។ ៧ខែក្រោយមក ស៊ុតនោះបានញាស់ចេញជាមនុស្ស ហើយព្រាន បានឲ្យឈ្មោះថា *ចៅប្រមាញ់វឹងស៊ុង*។

លុះអាយុ១៦ឆ្នាំ ចៅប្រមាញ់ វឹងស៊ុង ក៏សុំលាព្រានព្រៃជាឪពុក ដើម្បីស្វែងរកប្រពន្ធ។ ដើរមកដល់ស្រុកទ្រាំង ក៏បានប្រទះនឹងនាង *ត្រចើលដោះក្រាល* ហើយកើតចិត្តស្រលាញ់ចង់បានជាគូគ្រង។ ចៅប្រម៉ាញ់ វឹងសុង បាននិយាយនឹងយាយ *ស្រុង* ជាម្តាយឲ្យទៅស្តីដណ្តឹង។ ដោយយាយ *ស្រុង* ជីវភាពក្រីក្រ នាង ទែន ក៏បង្គាប់បញ្ជាឲ្យធ្វើរបងវាំងឆ្ងាយពីទ្វជុំវិញ សង់ប្រាសាទឲ្យនាង ត្រចើលនៅក្នុងវេលាតែមួយយប់ប៉ុណ្ណោះ ដើម្បីឲ្យចៅប្រម៉ាញ់ វឹងសុង លះបោះគំនិតចង់រៀបអាពាហ៍ពិពាហ៍នឹងនាង ត្រចើល នោះចោល។

យាយ ស្រុង បានប្រាប់ ចៅប្រមាញ់ វឹងសុង តាមដំណើររឿង។ ព្រឹកឡើង នាង ទែន ស្លន់តាំងគំនិត និតន័យដោយខ្លួននឹងនាង ត្រចើល នៅក្នុងរាំងបន្ទាយប្រាសាទ។ នាងទែន បានទៅហៅតាដុង នឹងយាយជ័យ ឲ្យមកដោះស្រាយបញ្ហា លុះមកដល់ពាក់កណ្តាលផ្លូវក៏វង្វេងផ្លូវ។ ពួកគាត់បានសួរក្មេងឃ្វាលគោ គេប្រាប់ថា តាដើរដោយជុំ នៅលើខ្នងន្ទី ចុះតាមទំនុង ជិតដល់ប្រាសាទ តំបន់គេហោង អស់ទេវតាផង រក្សាព្រៃព្រឹក។ លុះដល់ហើយ តានឹកគុណដោយប្រគុំភ្លេងថ្វាយ ១២១បទ ដោយផ្តើមថា ជ្រងអើយស្រងាត់ ដោះក្រាលមិនឃ្លាត កន្លែនទ្រាំងណា ភ្លេងខ្មោខ្នងន្ទី ឧត្តមថ្ងៃថ្លា...។ ភ្លេងផាត់ជាយ បន្ទាយប្រាសាទ ទឹកជាប់ ២ ស្អាតនិងភ្លេងក្រោមនាយ...ហើយយាយកុំភ្លេចបន់ ថ្វាយបទវង្វេងផង។ តាដុង យាយជ័យ បានធ្វើតាមក្មេងប្រាប់ ហើយក៏បានមក



www.elibraryofcambodia.org

*ឆយ ឃីហ៊ាង*

*ប្រែង ពិសិដ្ឋ　　លេង ណៃគីម*

*ម៉ិល វាសនា　　ភិនណារ៉ុង*

*ឈិត ភក្តី　　ជា មុនីឫទ្ធិ*

ដល់គ្នាមមួយរំពេចមែនៗ លុះដល់ពេលរៀបអាពាហ៍ពិពាហ៍ ចៅប្រមាញ់ វិងសុង និងនាងគ្រចើលដោះក្រាល តាដុង យាយជីយ បានឲ្យអ្នកភ្លេងចងជាភ្លេងតាមទម្រង់ការ ដូចជា បទជ្រង់ស្រងាត់ បទកន្លែន បទដោះក្រាល បទខ្លោ បទខ្នងន្តី បទរបងមាស បទបន្ទាយមាស បទទឹកជប់និងបតក្រោមនាយៗ តមក កបានជាបទភ្លេងទំនៀមក្នុងអាពាហ៍ពិពាហ៍ខ្មែររហូតមកៗ

លោកអាចារ្យ *សួរ លន់*[10] មានប្រសាសន៍ថា ពីមុនអាពាហ៍ពិពាហ៍ខ្មែរគ្មានភ្លេងកំដរទេ រហូតដល់អាពាហ៍ពិពាហ៍ចៅប្រមាញ់ វិងសុង និងនាងគ្រចើលដោះក្រាល ទើបមានភ្លេងកំដរៗ ចាប់ពីរពេលនោះមក ក្នុងពិធីអាពាហ៍ពិពាហ៍ខ្មែរមានភ្លេងកំដររហូតមកដល់សព្វថ្ងៃនេះៗ

ការរៀបរាប់ខាងលើបង្ហាញថា ពិធីសិរីសួស្តីក្នុងអាពាហ៍ពិពាហ៍ខ្មែរសុទ្ធតែជាប់ទាក់ទងរឿងព្រេងនិទានៗ វាបង្ហាញពីមូលដ្ឋាននិងបុព្វហេតុពីបុរាណនៃដំណើរការអាពាហ៍ពិពាហ៍ខ្មែរ មិនមែនធ្វើដោយគ្មានន័យខ្លឹមសារនោះទេៗ ហេតុនេះការបោះបង់កេច្ចពិធីណាមួយ គឺស្មើនឹងការបាត់បង់ខ្លឹមសារសិរីមង្គលមួយដែលក្នុងអាពាហ៍ពិពាហ៍នោះៗ

---

[10] លោកអាចារ្យ សួរ លន់ អាយុ៦៨ឆ្នាំ នៅភូមិភូមិអូរ ឃុំបឹងបត់កណ្ដាល ស្រុកបាកាន ខេត្តពោធិ៍សាត់(សម្ភាសន៍ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០០៧)



www.elibraryofcambodia.org

eBook នេះបង្កើតឡើងដោយ **មូលនិធិខ្មែរសម្រាប់ការសិក្សា** និង **ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

វាយបញ្ចូល ជា eBook ដោយ **ចាប រ៉ិចន**

ក្រោមការឧបត្ថម្ភពីសំណាក់ **ខ្មៅ ឃុន សំរ៉ែ**

ខែ មិនា ឆ្នាំ ២០១៣

www.elibraryofcambodia.org